# រឿង ចម្រៀងចាបដង្កូវ



រឿង ចម្រៀងចាបដង្កូវ

និពន្ធដោយអ្នកស្រី កែវ ណារុំ

គូររូបដោយលោក គឹម សុគន្ធ

រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA)

បោះពុម្ពឆ្នាំ២០១០

# រឿង ចម្រៀងចាបដង្កូវ



និពន្ធដោយ កែវ ណារុំ
វិចិត្ររូបភាពដោយ គីម សុគន្ធ
បោះពុម្ពផ្សាយដោយអង្គការសន្តិស្ម័គ្រចិត្ត

កំពុងតែយំរំអុកទារលុយពីម្ដាយទិញកាំភ្លើងជ័របាញ់ទឹក ស្រាប់តែពៅឈប់យំ ព្រោះចាបដង្កូវយំឮខ្លាំងពេក ។



ពៅសួរទៅម្ដាយថា "ចាបតូចហ្គឹងឈ្មោះអ្វី បានជាវាយំពីរោះម្ល៉េះ?"។
ម្ដាយឆ្លើយថា "ចាបតូចនេះឈ្មោះចាបផង្គូវ វាមិនយំទេគឺវាច្រៀង" ។





ពៅសួរទៀតថា "ចុះម៉េចបានជាអ្នកម៉ែ ថាវាច្រៀង?" ។ ម្ដាយឆ្លើយថា "ព្រោះវាបញ្ចេញសម្លេងពីរោះជាងកូនដែលយំរំខានដល់អ្នកដទៃ" ។

ពៅតបថា "អ៊ីចឹងថ្ងៃក្រោយ កូននឹងច្រៀងសុំលុយអ្នកម៉ែវិញឬ?" ។ ម្ដាយឆ្លើយថា"មិនបាច់ច្រៀងទេ គ្រាន់តែនិយាយឱ្យម៉ែស្ដាប់យល់បានហើយ"។





ម្ដាយពោលបន្តទៀតថា "កូនស្ដាប់វាច្រៀងចុះ វាច្រៀងតែបទដដែលៗ គឺសុំពីម៉ែឪវា តែនំចំណីញ៉ាំឱ្យឆ្អែតតែប៉ុណ្ណោះ" ។





ពៅនិយាយទៀតថា "វាមិនសុំខោអាវ ព្រោះវាមានស្លាបពាក់!" ។ ម្ដាយឆ្លើយថា "ត្រឹមត្រូវ! ចាបមានស្លាបពាក់តែមួយសម្រាប់ ។ ឯកូនមានខោអាវពេញទូ ក៏អត់ចេះស្កប់ សុំទិញឱ្យរហូត" ។





ពៅនិយាយបន្តទៀតថា "តាមអី វាអត់មានដៃកាន់កាំភ្លើង!" ។ ម្ដាយពោលតបវិញថា "កូនមានដៃលើសចាប គេទុកឱ្យកាន់ប៊ិច ខ្មៅដៃ មិនមែនសម្រាប់កាន់កាំភ្លើងបាញ់ទឹកប្រឡាក់អិដ្ឋពេញផ្ទះទេ!"។



ពេលឮការជជែកគ្នាដូច្នេះ បងស្រីពៅចេញមកនិយាយបន្ថែមថា "មែនហើយអ្នកម៉ែ! កូនចាបវាចេះជួយធ្វើការម៉ែឪវាទៀតន៎!" ។ ពៅពោលភ្លាមថា "ខ្ញុំមិនដែលឃើញទេ!" ។







បងស្រីតបវិញថា "កុំឆាប់ភ្លេចពេក! កាលពីថ្ងៃមុន បងបានប្រាប់អូនឯងឱ្យមើលកូនចាបជញ្ជូនស្មៅយកទៅធ្វើសំបុកនោះអ្វី?" ។ ពៅងក់ក្បាលហើយនិយាយថា "អូននឹកឃើញហើយ!" ។





ពៅសួរទៅបងស្រីគេថា "ចុះវាចេះធ្វើអ្វីទៀត?" ។ បងស្រីឆ្លើយថា "ចំពោះចាបវាមានមាឌតូច វាចេះតែច្រៀងក៏បានដែរ! អូនពៅមានមាឌធំជាងចាប តើគួរធ្វើអ្វីខ្លះ?" ។



ពៅជកដង្ហើមធំ រួចដើរទៅមាត់បង្អួចនិយាយជាមួយចាបថា "ចាបអើយ ចាបតូច! ឯងចេះច្រៀងពីរោះណាស់ ។ ខ្ញុំធំជាងឯង ខ្ញុំត្រូវចេះធ្វើអ្វីៗតាមអ្នកម៉ែ ដើម្បីឱ្យអ្នកម៉ែស្រឡាញ់ខ្ញុំ ដូចស្រឡាញ់ចម្រៀងឯងដែរណា៎!" ។







ពេលពៅនិយាយចប់ភ្លាម ស្រាប់តែកូនចាបច្រៀង ជីប!ជីប! ចេប!ចេប! ហើយស្ទុះហើរទៅពាំស្មៅយកទៅឱ្យម៉ែឪវា នៅលើដើមឈើដែលកំពុងចាក់កាច់ស្មៅធ្វើសំបុក ។ ពៅទះដៃសរសើរ ហើយនិយាយថា "កូនចាបបងល្អណាស់! ខ្ញុំធ្វើតាមបងឯងហើយ!"៕

∞∞∞ចប់∞∞∞





អង្គការសន្តិស្ម័គ្រចិត្ត
Shanti Volunteer Association